**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ១០........... **អយក.** សាណាប

# សេចក្តីណែនាំចំពោះបេក្ខជន
# ក្នុងការបំពេញ និងដាក់ពាក្យសុំអាហារូបករណ៍

យោង: សេចក្តីជូនដំណឹងលេខ.០៨អយក.សជណ ចុះថ្ងៃទី..១២ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧។

ដើម្បីបំពេញខ្លឹមសារក្នុងសំណុំពាក្យឱ្យបានត្រឹមត្រូវ បេក្ខជនត្រូវធ្វើតាមការណែនាំដូចមានខាងក្រោម:

**១**-មុននឹងសម្រេចសរសេរខ្លឹមសារចូលក្នុងសំណុំពាក្យ បេក្ខជនត្រូវគិតពិចារណាឱ្យបានច្បាស់លាស់ដោយធ្វើការសិក្សាលើគ្រប់ចំណុចដែលមានក្នុងសៀវភៅកម្រងព័ត៌មាន។ ក្នុងករណីមិនយល់ពីចំណុចណាមួយ អាចសាកសួរមន្ត្រីដែលទទួលបន្ទុកទទួលពាក្យនៅតាមវិទ្យាល័យ ឬនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ឬទំនាក់ទំនងជាមួយនាយកដ្ឋានឧត្តមសិក្សា តាមរយៈទូរស័ព្ទលេខ **០២៣ ២១៧ ៩៣៧** ឬជាមួយគ្រឹះស្ថានឧត្តមសិក្សាដែលបេក្ខជនបានដាក់ពាក្យសុំអាហារូបករណ៍ ដែលមានលេខទូរស័ព្ទនៅក្នុងសៀវភៅកម្រងព័ត៌មាន។

**២**-បេក្ខជនត្រូវសរសេរបំពេញសំណុំពាក្យរបស់ខ្លួនឲ្យបានគ្រប់ចំណុចត្រឹមត្រូវតាមការពិត និងច្បាស់លាស់ និងត្រូវផ្តល់ឯកសារភ្ជាប់បន្ថែមឱ្យបានគ្រប់ចំនួនតាមការកំណត់។ ចំពោះបេក្ខជនដែលសរសេរបំពេញមិនបានត្រឹមត្រូវក្នុងសំណុំពាក្យ មិនគ្រប់តាមចំណុច ឬផ្តល់ឯកសារបន្ថែមមិនគ្រប់គ្រាន់ **សំណុំពាក្យរបស់បេក្ខជននោះត្រូវបានចាត់ទុកថាពុំបានការ** ។

**៣**-បេក្ខជនចំណេះទូទៅ និងបំពេញវិជ្ជាដែលត្រូវប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ **២០១៦** ត្រូវបំពេញលេខបញ្ជីបេក្ខភាពរបស់ខ្លួនឱ្យបានត្រឹមត្រូវលើសំណុំពាក្យសុំអាហារូបករណ៍។ ចំពោះបេក្ខជនដែលបាន**ផ្ទេរការសិក្សា**ត្រូវសុំ**លេខតុបញ្ជីបេក្ខភាព**ថ្មីនៅវិទ្យាល័យថ្មីរបស់ខ្លួនពីមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ដែលគ្រប់គ្រងវិទ្យាល័យថ្មីនេះ។ ចំពោះបេក្ខជនស្វ័យរិន ក៏ត្រូវសុំមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ឱ្យចុះលេខរៀងដែលមានក្នុងបញ្ជីបេក្ខភាពផងដែរ។

**៤**-បេក្ខជនអាចស្នើសុំអាហារូបករណ៍ ក្នុងប្រភេទសិស្សអាទិភាពតំបន់ដាច់ស្រយាលបាន **លុះត្រាតែមានដើមកំណើត និងបានរៀនសូត្រ**នៅខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ឧត្តរមានជ័យ ព្រះវិហារ កោះកុង និងខេត្តប៉ៃលិន និងនៅតំបន់មួយចំនួនទៀតដែលជួបការលំបាកដូចមានចែងក្នុងឧបសម្ព័ន្ធក្នុងសៀវភៅកម្រងព័ត៌មាន។

**៥-បេក្ខជនអាចដាក់ស្នើសុំប្រភេទអាទិភាពចាប់ពី២ឡើងទៅ។**

**ឧទាហរណ៍៖ អាទិភាពនារី អាទិភាពក្រីក្រ។**



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh    គេហទំព័រ : www.moeys.gov.kh

**៦**-ការជ្រើសរើសមហាវិទ្យាល័យ ឬ ដេប៉ាតឺម៉ង់ ឬ ផ្នែក ឬ មុខជំនាញៈ បេក្ខជនត្រូវសរសេរឈ្មោះ មហាវិទ្យាល័យ ឬ ដេប៉ាតឺម៉ង់ ឬ ផ្នែក ឬ មុខជំនាញតែមួយដែលមានក្នុងសៀវភៅកម្រងព័ត៌មាន និងចុះលេខរៀងមហាវិទ្យាល័យ ឬ ដេប៉ាតឺម៉ង់ ឬ ផ្នែក ឬ មុខជំនាញនោះ ឱ្យបានត្រឹមត្រូវជាលេខអារ៉ាប់ទៅលើសន្លឹកពាក្យសុំអាហារូបករណ៍ និងបង្កាន់ដៃទទួលពាក្យសុំអាហារូបករណ៍ឱ្យដូចគ្នា។

ឧទាហរណ៍៖

| លេខរៀង (ល.រ) | មហាវិទ្យាល័យ/ដេប៉ាតឺម៉ង់/ផ្នែក/មុខជំនាញ |
|---|---|
| 12 | ទេសចរណ៍ |

**៧**- ក្នុងករណីដែលបេក្ខជនបំពេញព័ត៌មានពីការជ្រើសរើសអាទិភាពលើពាក្យសុំអាហារណ៍ និងបង្កាន់ដៃទទួលពាក្យសុំអាហារូបករណ៍មិនដូចគ្នា ឬសរសេរទឹកប៊ិចពណ៌ផ្សេងគ្នា ឬកោសលុប សំណុំពាក្យនោះនឹងត្រូវចាត់ទុកជាពុំបានការ។

**៨**-ចំពោះបេក្ខជនដែលបានដាក់ពាក្យសុំអាហារូបករណ៍ សិក្សាមុខជំនាញដែលតម្រូវឲ្យមានការប្រឡងសំណេរ ត្រូវយកសលាកបត្រឯកត្តជនពីវិទ្យាល័យមកបំពេញខ្លឹមសារ និងបិទរូបថតឱ្យបានត្រឹមត្រូវ ។ សលាកបត្រនេះ ត្រូវដកយកមកប្រគល់ឱ្យគ្រឹះស្ថានឧត្តមសិក្សា ដែលខ្លួនដាក់ពាក្យសុំប្រឡងអាហារូបករណ៍ណាមួយដាក់កំហិត ចាប់ពី**ថ្ងៃទី១៩ ដល់ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦** ចំនួន០១ច្បាប់ និង០១ច្បាប់ទៀតរក្សាទុកជាប់នឹងខ្លួន សម្រាប់បង្ហាញគណៈមេប្រយោគប្រឡងនៅថ្ងៃទី**០៦ ខែតុលា ឆ្នាំ២០១៦** នៅមណ្ឌលប្រឡង។ **ករណីមិនបានប្រគល់សលាកបត្រតាមការកំណត់នេះទេ នោះបេក្ខជនពុំអាចចូលប្រឡងបានឡើយ**។ បេក្ខជនត្រូវមកមើលឈ្មោះប្រឡងនៅថ្ងៃទី**២៩ ខែកញ្ញា ឆ្នាំ២០១៦** ចាប់ពីម៉ោង២:០០នាទីរសៀល នៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលខ្លួនស្នើសុំអាហារូបករណ៍។

**៩**-សិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា រូបវិទ្យា និងអក្សរសិល្ប៍ខ្មែរ ដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ**២០១៦** មានសិទ្ធិជាប់អាហារូបករណ៍ដោយស្វ័យប្រវត្តិចំនួន**មួយកន្លែង** ចូលរៀនតាមផ្នែកពូកែរបស់ខ្លួនដូចមានការកំណត់ក្នុងសៀវភៅកម្រងព័ត៌មានដែលមានសញ្ញាផ្កាយ(*) លក្ខខណ្ឌមុខវិជ្ជានិទ្ទេសតាមមុខវិជ្ជា និទ្ទេសរួម និងចំនួនជ្រើសរើសនិស្សិតអាហារូបករណ៍ សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ ។ សិទ្ធិនេះ ត្រូវបានរក្សាទុកនៅពេលណាសិស្សពូកែទាំងនោះ បានមកដាក់ពាក្យសុំអាហារូបករណ៍នៅ**តាមមន្ទីរអប់រំ យុវជន និងកីឡា ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦**។ ក្នុងករណីសិស្សពូកែទូទាំងប្រទេសមិនចង់ទទួលអាហារូបករណ៍ដោយស្វ័យប្រវត្តិដូចដែលបានកំណត់ក្នុងកូនសៀវភៅកម្រងព័ត៌មាន សិស្សពូកែទាំងនោះ ត្រូវដាក់ពាក្យសុំអាហារូបករណ៍នៅតាមវិទ្យាល័យ ឬតាមមន្ទីរអប់រំ យុវជន និងកីឡា ដូចជាសិស្សទូទៅដែរ។

**១០**-ការប្រគល់សំណុំពាក្យឱ្យទៅវិទ្យាល័យ ឬឱ្យទៅមន្ទីរអប់រំ យុវជន និងកីឡាវិញ មិនបានទាន់ពេលវេលាតាមការកំណត់ ត្រូវបានចាត់ទុកថា បេក្ខជននោះបានបោះបង់បេក្ខភាពរបស់ខ្លួន។

**១១**-សំណុំពាក្យដែលបេក្ខជនបានបំពេញខ្លឹមសាររួចហើយ និងបានប្រគល់មកដល់នាយកដ្ឋានឧត្តមសិក្សារួចហើយ នោះពុំអាចស្នើសុំយកទៅកែ ឬ ផ្លាស់ប្តូរខ្លឹមសារបានឡើយ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា បេក្ខជនទាំងពីរភេទដែលកំពុងត្រៀមខ្លួនស្នើសុំអាហារូបករណ៍ចូលរៀនថ្នាក់បរិញ្ញាបត្រសម្រាប់ឆ្នាំសិក្សា **២០១៦-២០១៧** នៅតាមគ្រឹះស្ថានឧត្តមសិក្សា នឹងអនុវត្តតាមសេចក្តីណែនាំនេះដោយស្មារតីយកចិត្តទុកដាក់បំផុត។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៦

**ឧ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

យក់ ឌីយ